# ឆ្លើយតបនឹងញត្តិ

## រៀបចំឯកសារជាភាសាអង់គ្លេសនិងបារាំងកំណត់សញ្ញាជា ឯកសារដើម ឬ បកប្រែ

ញត្តិលេខ៖ ៤២១-០៣០៥៤

ដោយ៖ លោកម៉ិកគិនណុន មណ្ឌលខោកគ្វីតឡាំ-ផតខោកគ្វីតឡាំ

ថ្ងៃខែឆ្នាំ៖ ៧ ធ្នូ ២០១៨

ឈ្មោះជាអក្សរធំនៃហត្ថលេខា៖ ចុះហត្ថលេខាដោយអ្នកស្រីគ្រីស្ទា ហ្វ្រីឡែន

ឆ្លើយតបដោយរដ្ឋមន្ត្រីក្រសួងការបរទេស

ចុះហត្ថលេខា៖ រដ្ឋមន្ត្រីឬលេខាធិការរដ្ឋសភា

ប្រធានរឿង៖ ប្រទេសកម្ពុជា

ឯកសារដើម

ការឆ្លើយតប៖

ការលើកកំពស់និងការការពារនូវសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋគឺជាផ្នែកសមាហរណកម្មសំខាន់ក្នុងទំនាក់ទំនងទ្វេភាគីរវាងកាណាដានិងកម្ពុជា។

កាណាដាមានក្តីកង្វល់យ៉ាងខ្លាំងនូវទង្វើប្រឆាំងលទ្ធិប្រជាធិបតេយ្យដែលប្រព្រឹត្តឡើងដោយរដ្ឋាភិបាលកម្ពុជា។ ការរំលាយគណបក្សសង្គ្រោះជាតិកាលពីខែវិច្ឆិការ ឆ្នាំ២០១៧ ដោយតុលាការកំពូលនិងការចាប់មេដឹកនាំរបស់ពួកគេ គឺជាការប៉ុនប៉ងបែបគិតទុកជាមុនក្នុងការកំហិតទស្សនៈនយោបាយផ្ទុយគ្នា ការយកសារព័តមាននិងអង្គការមិនមែនរដ្ឋាភិបាលជាមុខព្រួញគឺជាសញ្ញាបញ្ជាក់ថារដ្ឋាភិបាលមិនទទួលស្គាល់កាន់តែខ្លាំងឡើងនូវនីតិវិធីដំណើរការលទ្ធិប្រជាធិបតេយ្យ។

ឆ្លើយតបទៅនឹងការវិវឌ្ឍន៍ប្រកបដោយបញ្ហាទាំងនេះ ការិយាល័យកិច្ចការពិភពលោកប្រទេសកាណាដាបានចេញនូវសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ចំថ្ងៃបោះឆ្នោតសាកល អំពាវនាវអោយដោះលែងលោកកឹម-សុខា ប្រធានគណបក្សសង្គ្រោះជាតិ។ ប្រទេសកាណាដាបានសំដែងក្តីកង្វល់របស់ខ្លួនយ៉ាងជ្រាលជ្រៅចំពោះការបោះឆ្នោតមិនប្រកបដោយលទ្ធិប្រជាធិបតេយ្យទាំងនេះ ដោយកត់សំគាល់ឃើញយ៉ាងទូលាយថាការឃោសនារកសំលេងឆ្នោតបានរារាំងដោយការគំរាមកំហែងអ្នកបោះឆ្នោត និងការបំភ្លៃនូវលទ្ធផលឆ្នោត។ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៨ លោកកឹម-សុខាត្រូវបានដោះលែងពីពន្ធនាគារ អោយស្ថិតក្រោមការត្រួតពិនិត្យបន្ទាប់ពីឃុំខ្លួនអស់រយៈពេលមួយឆ្នាំ អោយស្ថិតក្រោមលក្ខខណ្ឌដែលស្មើនឹងការឃុំខ្លួនក្នុងផ្ទះដោយបំបិទសិទ្ធិការទាក់ទងមកខាងក្រៅទាំងស្រុង។

តាមរយៈការវិវឌ្ឍន៍ចុងក្រោយបំផុត រដ្ឋាភិបាលកាណាដាបានចេញសារតាមបណ្តាញទ្វីតតើរកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ ទទួលស្គាល់ការដោះលែងលោកកឹម-សុខាពីពន្ធនាគារ ប៉ុន្តែអំពាវនាវអោយទំលាក់ចោលបទចោទទាំងបំពាននិងខ្វះមូលដ្ឋានប្រឆាំងនឹងរូបគាត់ទាំងនោះចេញ។ រដ្ឋាភិបាលកាណាដាបានជំរុញបន្ថែមដល់រដ្ឋាភិបាលកម្ពុជាអោយមានការដំណើរការគណបក្សសង្គ្រោះឡើងវិញនិងរៀបចំការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

កាណាដានឹងបន្តលើកឡើងនូវបញ្ហានេះជាមួយភាគីកម្ពុជានូវគ្រប់កំរិតថ្នាក់ ហើយនឹងធ្វើយុទ្ធនាការភាពគ្មានទោសទណ្ឌរបស់លោកកឹម-សុខា និងការហាមប្រាមដល់មន្ត្រីសំខាន់ៗទាំង១១៨នាក់របស់គណបក្សសង្គ្រោះជាតិអោយមានការផ្តល់សម្បទាឡើងវិញ។

រដ្ឋាភិបាលរបស់យើងនៅតែតាំងចិត្តខ្ពស់ចំពោះការលើកកំពស់យុត្តិធម៌អន្តរជាតិនិងគោរពសិទ្ធិមនុស្ស ប្រឆាំងអំពើពុករលួយ រួមបញ្ចូលទាំងប្រទេសកម្ពុជា។

*បកប្រែក្រៅផ្លូវការដោយលោកសេង-សុភ័ណ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩*